ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៩-០៩-១៦៦ ប្រ.ក

# ប្រកាស
## ស្តីពី
## ការបង្កើតក្រុមការងារគ្រប់គ្រងអាជីវករប្តូរប្រាក់ និងដេញថ្លៃរូបិយប័ណ្ណ

---

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៨៩៧/០៣ ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងការប្តូរប្រាក់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/៥២៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការតែងតាំង ឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- យោងតាមការសំរេចរបស់អង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩

## ស ម្រេ ច

**ប្រការ ១.-**

បង្កើតក្រុមការងារគ្រប់គ្រងអាជីវករប្តូរប្រាក់ និងដេញថ្លៃរូបិយប័ណ្ណ ដែលមានសមាសភាព ដូចខាងក្រោម :

| | | |
|---|---|---|
| ១. លោកស្រី ស្រី ស៊ីយុត | ប្រធាននាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ | ប្រធាន |
| ២. លោកស្រី សាយ សំអាត | អនុប្រធាននាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ | អនុប្រធាន |
| ៣. លោកស្រី ស៊ិន រាំរី | ប្រធានការិយាល័យ | សមាជិក |

| | | |
|---|---|---|
| ៤. លោកស្រី គូវ ម៉ាលី | ប្រធានការិយាល័យ | សមាជិក |
| ៥. លោកស្រី ខាំ សុភី | ប្រធានការិយាល័យ | សមាជិក |
| ៦. លោក ឈឹម និមល | អនុប្រធានការិយាល័យ | សមាជិក |
| ៧. លោក ម៉ៅ សុកានីន | អនុប្រធានផ្នែក | សមាជិក ។ |

**ប្រការ ២.—**

ក្រុមការងារនេះ មានមុខងារភារកិច្ច ដូចតទៅ :

ការងារគ្រប់គ្រងអាជីវករប្តូរប្រាក់ :

- រៀបចំក្រមប្រតិបត្តិសម្រាប់អាជីវករប្តូរប្រាក់ (Code of Conduct for Money Changer)
- ពិចារណាលើការបង្កើតសមាគមអាជីវកម្មប្តូរប្រាក់
- រៀបចំឡើងវិញនូវបទប្បញ្ញត្តិសម្រាប់គ្រប់គ្រងអាជីវកម្មប្តូរប្រាក់
- តាមដាន និងត្រួតពិនិត្យ ប្រតិបត្តិការរបស់អាជីវករប្តូរប្រាក់
- តាមដានការផ្តល់របាយការណ៍របស់អាជីវករប្តូរប្រាក់
- រៀបចំបទប្បញ្ញត្តិ និងសេចក្តីណែនាំផ្សេងៗដែលពាក់ព័ន្ធនឹងអាជីវកម្មប្តូរប្រាក់ ។

ការងារដេញថ្លៃរូបិយប័ណ្ណ :

- រៀបចំរចនាសម្ព័ន្ធ និងនីតិវិធីនៃការដេញថ្លៃរូបិយប័ណ្ណ ឱ្យមានប្រសិទ្ធភាព ដោយសម្របសម្រួលរវាងគោលនយោបាយរូបិយវត្ថុ និងគោលនយោបាយប្តូរប្រាក់
- សម្របសម្រួលជាមួយក្រុមការងារពាក់ព័ន្ធ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តគោលនយោបាយរូបិយវត្ថុ
- ពិចារណាលើការត្រួតពិនិត្យ ដើម្បីធានានូវការគោរពតាមក្រមប្រតិបត្តិ និងបទបញ្ជាផ្សេងៗទៀត ។

**ប្រការ ៣.—**

ក្រុមការងារនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន និងត្រូវធ្វើរបាយការណ៍ជូនគណៈកម្មការប្រតិបត្តិ រៀបចំទីផ្សារអន្តរធនាគារ និងប្តូរប្រាក់ ។

**ប្រការ ៤.—**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តនូវខ្លឹមសារនៃប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាពខ្ពស់ ។

**ប្រការ ៥.—**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។៚

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ មិថុនា ឆ្នាំ ២០០៩

ទេសាភិបាល

ជា-ចាន់តូ

<u>កន្លែងទទួល</u>

- ដូចប្រការ ៥ " ដើម្បីអនុវត្ត "
- កាលប្បវត្តិ
- ឯកសារ

<u>ចម្លងជូន</u>

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"
- សាម៉ីជន